# សេចក្តីសង្ខេបពិស្តារ

ពលកម្មកុមារបង្កឱ្យមានឧបសគ្គជាច្រើនក្នុងការសំរេចបាននូវការអប់រំថ្នាក់បឋមសិក្សាជាសាកល និង បង្កឧបសគ្គដល់ការសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សន៍កម្ពុជា។ ពលកម្មកុមារ មិនត្រឹមតែបង្កឱ្យមានផលប៉ះពាល់ដល់សុខមាលភាពរបស់កុមារគ្រប់រូបនោះទេ វាថែមទាំងបន្ថយល្បឿននៃកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍប្រទេស ។ កុមារត្រូវបានបង្ខំឱ្យបោះបង់ចោលការសិក្សា និងត្រូវធ្វើការងារដើម្បីជួយរកប្រាក់ចំណូលដល់គ្រួសារ។ កុមារមិនបានទទួលនូវឱកាសរៀនសូត្រជំនាញ និងចំណេះដឹងនានាសំរាប់ស្វែងរកអនាគតការងារឡើយ ដូច្នេះ ទើបកុមារស្ថិតជាប់នៅក្នុងវដ្តនៃភាពក្រីក្រ ។ ភស្តុតាងជាក់ស្តែងបង្ហាញថា ការចូលធ្វើការរបស់កុមារ បង្កឱ្យមាននូវផលប៉ះពាល់អវិជ្ជមានជាច្រើនដល់ការចូលរៀនរបស់កុមារ និងដល់លទ្ធផលនៃការសិក្សារបស់កុមារនៅក្នុងបរិបទនៃប្រទេសកម្ពុជា ។ ការកាត់បន្ថយពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា នឹងជំរុញដល់ការអភិវឌ្ឍន៍ធនធានមនុស្សបានមួយផ្នែកធំ និងចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។ ការកាត់បន្ថយពលកម្មកុមារ ក៏អាចជួយសំរួលដល់បន្ទុកការងាររបស់ពលករដែលមិនមានជំនាញគ្រប់គ្រាន់ក្នុងវិស័យសេដ្ឋកិច្ចដែលបង្កឱ្យមានភាពក្រីក្រផងដែរ។ ការកាត់បន្ថយពលកម្មកុមារ ក៏អាចជួយពង្រឹងនូវសមត្ថភាពផលិតក្នុងបរិដ្ឋានដែលកំពុងវិវត្តន៍ផ្លាស់ប្តូរទៅមុខផងដែរ ។

របាយការណ៍ថ្មី១ស្តីពីពលកម្មកុមារ ក៏ត្រូវបានបង្កើតឡើងក្រោមជំនួយឧបត្ថម្ភពីគំរោងស្តីពីការស្វែងយល់ពីការងាររបស់កុមារ (UCW)។ គំរោងស្រាវជ្រាវនេះគឺជាគំនិតផ្តួចផ្តើមរួមគ្នារវាងអង្គការពលកម្មអន្តរជាតិ (ILO) អង្គការយូនីសេហ្វ (UNICEF) និង ធនាគារពិភពលោក។ នេះគឺជាលទ្ធផលនៃការសហការរួមគ្នាពីសំណាក់ វិជ្ជាស្ថានស្ថិតិជាតិ ក្រសួងពាក់ព័ន្ធ ស្ថាប័នស្រាវជ្រាវ លេខាធិការដ្ឋាននៃគំរោង UCW ការិយាល័យប្រចាំនៅប្រទេសកម្ពុជារបស់អង្គការ ILO-IPEC អង្គការ UNICEF និង ធនាគារពិភពលោក ។

របាយការណ៍នេះ បង្ហាញពីស្ថានភាពទូទៅនៃបញ្ហាពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា រួមមានដូចជាកំរិតស្ថានភាពនៃពលកម្មកុមារ មូលហេតុ និងផលប៉ះពាល់នៃពលកម្មកុមារទៅលើសុខភាព និងការអប់រំរបស់កុមារ ។ របាយការណ៍នេះ ក៏បានបង្ហាញពីការឆ្លើយតបថ្នាក់ជាតិចំពោះបញ្ហាពលកម្មកុមារ និងបង្ហាញពីគោលនយោបាយថ្នាក់ជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ។ របាយការណ៍នេះមានគោលបំណង ៣ ធំ១ គឺ (១) ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព័ត៌មានស្តីពីពលកម្មកុមារ (២) ដើម្បីលើកកំពស់ការពិភាក្សាទៅលើគោលនយោបាយលុបបំបាត់ពលកម្មកុមារ និងពិចារណាទៅលើការរីកចំរើននានាក្នុងការកាត់បន្ថយពលកម្មកុមារនៅថ្នាក់ជាតិ (៣) ដើម្បីកសាងសមត្ថភាពនៅថ្នាក់ជាតិស្តីពីការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យជាប្រចាំទៅ

លើបញ្ហាពលកម្មកុមារ ។

## ការចូលរួមរបស់កុមារក្នុងការងារ

**ការចូលរួមរបស់កុមារក្នុងសកម្មភាពសេដ្ឋកិច្ច មានកើតឡើងនៅទូទាំងប្រទេសកម្ពុជា ។** ជារួម ក្នុងចំណោមកុមារចំនួន ១,៤ លាននាក់ មានកុមារដែលមានអាយុចាប់ពី ៧-១៤ ឆ្នាំប្រមាណជា ៥២ ភាគរយ បានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច បើយោងតាមឯកសារឆ្នាំ ២០០១។ បើប្រៀបធៀបនឹងប្រទេសដទៃទៀតដែលមានកំរិតនៃប្រាក់ចំណូលប្រហាក់ប្រហែលគ្នា ចំនួនភាគរយនេះមានកំរិតខ្ពស់។ នេះបង្ហាញថាបញ្ហាពលកម្មកុមារដែលកើតមាននៅក្នុងប្រទេសកម្ពុជា គឺជាបញ្ហាមួយដែលត្រូវចាប់អារម្មណ៍។ មានភស្តុតាងបញ្ជាក់ថា ការចូលរួមរបស់កុមារក្នុងសកម្មភាពសេដ្ឋកិច្ចមានការធ្លាក់ចុះ ចំណែកឯការចុះឈ្មោះចូលរៀនរបស់កុមារមានការកើនឡើងចាប់តាំងពីឆ្នាំ ២០០១ ។ ប៉ុន្តែដោយសារតែបញ្ហាទិន្នន័យ វាលំបាកក្នុងការវាយតំលៃប្រកបដោយការជឿជាក់ ទៅលើនិន្នាការធ្វើការងាររបស់កុមារណាស់។

**ការចូលរួមរបស់កុមារក្នុងសកម្មភាពសេដ្ឋកិច្ច ចាប់ផ្តើមតាំងពីក្មេង ហើយកើនឡើងយ៉ាងខ្លាំងទៅតាមកំរិតអាយុ។** ប្រការនេះគឺជាមូលហេតុដែលបណ្តាលឱ្យកុមារមិនងាយនឹងបានចូលរៀនក្នុងវ័យក្មេង ហើយឆាប់បោះបង់ចោលការសិក្សា។ កុមារចំនួន ១៦ ភាគរយ បានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចតាំងពីអាយុ ៦ ឆ្នាំ ។ កុមារចំនួនប្រមាណជាពាក់កណ្តាល បានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចតាំងពីអាយុ ១០ ឆ្នាំ ។ ដល់អាយុ ១៥ ឆ្នាំ ចំនួនកុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច មានច្រើនជាងចំនួនកុមារដែលបានចូលរៀន។ ម្យ៉ាងវិញទៀត ការចុះឈ្មោះចូលរៀនរបស់កុមារ ឈានដល់កំរិតកំពូលក្នុងអាយុ ១១ ឆ្នាំ ប៉ុន្តែវត្តមានរបស់កុមារក្នុងសាលារៀនធ្លាក់ចុះ ព្រោះកុមារត្រូវឈប់រៀន និងចាប់ផ្តើមចូលធ្វើការងារ។ សមាមាត្រនៃចំនួនកុមារដែលកំពុងសិក្សា និងមិនត្រូវធ្វើការងារ បានកើនឡើងដល់កំរិតកំពូលមានចំនួន ៤៩ ភាគរយ ក្នុងអាយុ ៩ ឆ្នាំ ។

សមាមាត្រកុមារដែលចូលរួមក្នុងសកម្មភាពមិនមែនផ្នែកសេដ្ឋកិច្ច ជាពិសេសធ្វើការងារផ្ទះ មានចំនួនច្រើន។ កុមារអាយុ ៧ ដល់ ១៤ ឆ្នាំ ប្រមាណជា ៧៩ ភាគរយ បានចូលរួមធ្វើការងារផ្ទះជាប្រចាំសប្តាហ៍ នេះបើយោងទៅតាមឯកសារឆ្នាំ ២០០១។ កុមារចាប់ផ្តើមធ្វើការងារផ្ទះតាំងពីនៅក្មេង ប៉ុន្តែមិនសូវធ្វើច្រើនណាស់ណានោះទេ។ កុមារម្នាក់ក្នុងចំណោមកុមារ ២ នាក់ ធ្វើការងារ "២ មុខ" គឺធ្វើការងារផ្ទះផង និង ចូលរួមសកម្មភាពផ្នែកសេដ្ឋកិច្ចផង រៀងរាល់សប្តាហ៍ ។

## ការចូលរួមរបស់កុមារក្នុងពលកម្មកុមារ

**ការចូលរួមរបស់កុមារក្នុងពលកម្មកុមារ — ទស្សនាទានផ្នែកច្បាប់ដែលឆ្លុះបញ្ចាំងពីការបែងចែកការងារដែលមានគ្រោះថ្នាក់ ដែលមានផលអវិជ្ជមាន និង ដែលកុមារមិនចង់បាន ក៏មានកំរិតខ្ពស់ផងដែរ។** កុមារដែលចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រមាណជា ៧៥០,០០០នាក់ មានអាយុក្រោមអាយុអប្បបរមា គឺក្រោមអាយុ ១២ ឆ្នាំ។ កុមារ (ដែលមានអាយុ ១២-១៤ ឆ្នាំ) ប្រមាណជា ៥០០,០០០ នាក់បន្ថែមទៀត បានចូលរួមក្នុងសកម្មភាពផ្នែកសេដ្ឋកិច្ចស្រាល ហើយមានអាយុក្រោមអាយុអប្បបរមាសំរាប់ធ្វើការងារប្រភេទនេះ។ កុមារដែលមានអាយុចាប់ពី (១៥-១៧ ឆ្នាំ) ប្រមាណជា ២៥០,០០០ នាក់ បានចូលរួមក្នុងវិស័យការងារដែលត្រូវបានចាត់ទុកថាមានគ្រោះថ្នាក់នៅថ្នាក់ចំនួន ៦ ក្នុងចំណោមវិស័យដែលគ្រោះថ្នាក់ចំនួន ១៦ ហើយទិន្នន័យបានបង្ហាញថាកុមារទាំងនេះកំពុងធ្វើការចំនួន ៤៣ ម៉ោង ឬ ច្រើនជាងនេះក្នុង ១ សប្តាហ៍ ។ ប្រសិនបើសរុបតួលេខនៃក្រុមទាំងនេះជាមួយគ្នា គេអាចប៉ាន់ស្មានបានថាមានកុមារដែលមានអាយុចាប់ពី ៧-១៧ ឆ្នាំចំនួន ១,៥ លាននាក់ បានចូលរួមក្នុងពលកម្មកុមារ គឺមានប្រមាណជា ៤០ ភាគរយនៃក្រុមនេះ។ គេអាចសង្កត់ធ្ងន់បានថា តួលេខនេះធ្វើឡើងក្នុងកំរិតទាប ព្រោះវាមិនបានរាប់បញ្ចូលនូវវិស័យដែលមានគ្រោះថ្នាក់នៅថ្នាក់ជាតិទាំង ១៦ និង មិនបានរាប់បញ្ចូលនូវទំរង់ធ្ងន់ធ្ងរដែលមិនអាចទទួលយកបាននៃពលកម្មកុមារ។ ភស្តុតាងដែលទទួលបានពីការអង្កេតវាយតំលៃយ៉ាងរហ័សមួយ និងភស្តុតាងដែលទទួលបានពីប្រភពផ្សេងៗទៀត បានបង្ហាញថា កុមារដែលបានចូលរួមក្នុងទំរង់ធ្ងន់ធ្ងរដែលមិនអាចទទួលយកបាន មានចំនួនសមាមាត្រតូច បើប្រៀបទៅនឹងតួលេខសរុបនៃពលកម្មកុមារ។ មិនមានស្ថិតិជាក់លាក់ស្តីពីចំនួនកុមារដែលបានចូលរួមក្នុងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារទេ។

## លក្ខណៈនៃការងាររបស់កុមារ

**កុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចភាគច្រើន ត្រូវបានរកឃើញនៅតាមទីស្រែចំការ និង កំពុងធ្វើការឱ្យគ្រួសាររបស់ខ្លួន។** ក្នុងចំណោមកុមារ ៤ នាក់ដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច មានកុមារចំនួន ៣ ភាគ ៤ ចូលរួមក្នុងវិស័យកសិកម្ម ចំនួន ១៥ ភាគរយចូលរួមក្នុងវិស័យពាណិជ្ជកម្ម ចំនួន ៥ ភាគរយចូលរួមក្នុងវិស័យផលិតកម្ម និងចំនួន ២ ភាគរយចូលរួមក្នុងវិស័យសេវាកម្ម។ កុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រមាណជា ៩០ ភាគរយ ធ្វើការឱ្យគ្រួសាររបស់ខ្លួនដោយមិនយកកំរៃ។ កុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រមាណជា ៧ ភាគរយ ធ្វើការជាអ្នកលក់កំលាំងពលកម្មប្រចាំថ្ងៃជាធម្មតា។ កុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រមាណជា ២ ភាគរយ ធ្វើការជាបុគ្គលិកដែលទទួលប្រាក់បៀវត្សនៅក្នុងវិស័យរៀបរយ។

វិស័យរៀបរយនេះ ត្រូវបានគ្របដណ្តប់ដោយបទបញ្ញត្តិស្តីពីពលកម្មកុមារដែលមាននៅក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

**សំរាប់កុមារដែលបានរាយការណ៍ថាចេះធ្វើការដោយទទួលបានជាសំណងឬជាសាច់ប្រាក់ ជាទូទៅការងាររបស់កុមារទាំងនេះ (ទទួលបានជាសំណង ឬ ជាសាច់ប្រាក់) មានសារៈសំខាន់ណាស់សំរាប់ក្រុមគ្រួសាររបស់ពួកគេ។** កុមារអាចរកប្រាក់បានជាមធ្យមចំនួន ១ ដុល្លារក្នុង ១ ថ្ងៃ ដែលស្មើនឹង ២៨ ភាគរយនៃប្រាក់ចំណូលសរុបក្នុងគ្រួសារ។ ប្រសិនបើយើងប្រើលុយនេះជាវិធានការមួយសំរាប់វាស់ទៅលើចំណាយឱកាសនៃការសិក្សា និង ប្រៀបធៀបលុយនេះទៅនឹងចំណាយសរុបសំរាប់ការសិក្សា យើងឃើញថា លុយនេះគឺជាផ្នែកដ៏សំខាន់សំរាប់ជួយដល់ការចំណាយសរុបនៃថ្លៃសិក្សា និង ជារនាំងដ៏សំខាន់មួយក្នុងការរារាំងកុមារក្រីក្រមិនឱ្យទទួលបានការសិក្សា។

**ការងារធ្វើឱ្យកុមារចំណាយពេលវេលាអស់យ៉ាងច្រើន។** កុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចដែលមានអាយុចាប់ពី ៧-១៤ ឆ្នាំ ជាទូទៅបំពេញការងារចំនួន ២២ ម៉ោងក្នុងមួយសប្តាហ៍ ។ ក្រុមកុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចផង និង បានចូលរួមក្នុងការសិក្សាផង ជាទូទៅចំណាយពេលចូលរួមក្នុងវិស័យសេដ្ឋកិច្ចតិចជាង គឺជាមធ្យមចំនាយពេលអស់ ២០ ម៉ោងក្នុងមួយសប្តាហ៍។ ការចំណាយពេលវេលានេះ មានកំរិតទាបជាងការចំណាយពេលវេលាក្នុងការសិក្សា ដែលមានជាមធ្យមចំនួន ២៣,៥ ម៉ោងក្នុងមួយសប្តាហ៍។ បន្ទុកការងារសរុបរបស់កុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច មានការកើនឡើងគួរឱ្យកត់សំគាល់ នៅពេលដែលគិតពិចារណាទៅលើសកម្មភាពមិនមែនផ្នែកសេដ្ឋកិច្ចដែលកុមារបានបំពេញ ។ សកម្មភាពមិនមែនផ្នែកសេដ្ឋកិច្ច បន្ថែមបន្ទុកការងារទៅលើកុមារចំនួន ៨ ម៉ោងថែមទៀតក្នុងមួយសប្តាហ៍ដល់កុមារដែលចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចដែលមានអាយុចាប់ពី ៧-១៤ ឆ្នាំ ។ ដូច្នេះកុមារទាំងនេះចូលរួមធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ៣១ ម៉ោង។

**សមាមាត្រខ្ពស់នៃកុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ប្រឈមមុខនឹងគ្រោះថ្នាក់ដែលបណ្តាលមកពីការងារ** និងធ្វើឱ្យពួកគេងាយរងរបួស និងងាយធ្លាក់ខ្លួនឈឺ។ មនុស្សធំដែលបានសំភាសន៍ក្នុង CCLS ឆ្នាំ ២០០១ បានរាយការណ៍ថា ក្នុងចំណោមកុមារ ៣ នាក់ មានកុមារ ២ នាក់ ដែលមាន"ស្ថានភាពការងារប្រកបដោយគ្រោះថ្នាក់" ឬ (មាន ៦១ ភាគរយ)។ កុមារធ្វើការជាច្រើន មិនសូវមានការការពារនៅកន្លែងការងារច្រើន

ដូចមនុស្សធំនោះទេ។ ពាក់កណ្ដាលនៃចំនួនកុមារសរុប មិនបានប្រើប្រាស់ឧបករណ៍សុវត្ថិភាពទេ ទោះបីជាមានការបង្ហាញថាឧបករណ៍ទាំងនេះមានអត្ថប្រយោជន៍ច្រើនក៏ដោយ ។

## ផលប៉ះពាល់នៃការងាររបស់កុមារ

**ការងាររបស់កុមារ គឺជាកត្តាគន្លឹះដែលបង្កឱ្យមាននូវបញ្ហាប្រឈមមុខពាក់ព័ន្ធសំខាន់ៗចំនួន ២ ដែលប៉ះពាល់ដល់ប្រព័ន្ធអប់រំជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា៖ ទីមួយគឺកុមារមិនងាយនឹងបានចូលរៀនក្នុងវ័យក្មេង និង ទីពីរគឺកុមារឆាប់បោះបង់ចោលការសិក្សានៅក្នុងបឋមសិក្សាក៏រិតខ្ពស់។** គំរូភស្តុតាងមួយត្រូវបានធ្វើឡើងដើម្បីសិក្សាពីផលប៉ះពាល់នៃការងាររបស់កុមារទៅលើការអប់រំ ដោយបានបង្ហាញថា ការចុះឈ្មោះចូលរៀនរបស់កុមារមានទំនាក់ទំនងជាអវិជ្ជមានជាមួយនឹងការធ្វើការងាររបស់កុមារ ជាពិសេសគឺទំនាក់ទំនងរវាងការចូលរៀន និងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច។ ទំនាក់ទំនងរវាងការចុះឈ្មោះចូលរៀន និងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច មានភាពអវិជ្ជមានទៅតាមអាយុ ជាពិសេសក្នុងចំណោមក្មេងស្រី។ ប្រការនេះបញ្ជាក់ថាកំរិតនៃការផ្លាស់ប្តូរ និងកំរិតនៃការជំនួសរវាងការចូលរៀន ទៅជាការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច មានការកើនឡើង នៅពេលដែលកុមារមានអាយុកាន់តែច្រើន ។ និន្នាការនេះកើតឡើងពិតប្រាកដ ជាពិសេសក្នុងចំណោមក្មេងស្រី។ លទ្ធផលនៃការសិក្សាប៉ាន់ស្មានក៏បានបញ្ជាក់ផងដែរថា ការងារប៉ះពាល់ដល់ការចុះឈ្មោះចូលរៀនឱ្យបានទាន់ពេល (ឬរារាំងកុមារមិនឱ្យចូលរៀន)។ ហើយ ប្រការនេះបានកាត់បន្ថយនូវលទ្ធភាពរបស់កុមារក្នុងការបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សារបស់ពួកគេ។

**ការវិភាគបន្ថែមទៀតបានបង្ហាញថា ការងាររបស់កុមារមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើលទ្ធផលនៃការសិក្សារបស់កុមារ** តាមការវាស់វែងទៅលើពិន្ទុប្រលងអក្ខរកម្ម និងពិន្ទុប្រលងលេខ។ ក្នុងចំណោមសិស្សថ្នាក់ទី ៤ ការធ្វើការងាររាល់ថ្ងៃមុននឹងទៅសាលារៀន បានកាត់បន្ថយនូវពិន្ទុប្រលងអក្ខរកម្ម និងពិន្ទុប្រលងលេខ ចំនួន ៩ ភាគរយ ទោះបីជាមានការត្រួតពិនិត្យទៅលើគុណភាពនៃសិក្សាក៏ដោយ។ ការរកឃើញនេះបានបង្ហាញពីស្ថានភាពពិតប្រាកដដែលថា ការងារមិនត្រឹមតែប៉ះពាល់ដល់សមត្ថភាពរបស់កុមារក្នុងការចុះឈ្មោះចូលរៀន និងបន្តនៅសិក្សានោះទេ ប៉ុន្តែវាថែមទាំងប៉ះពាល់ដល់សមត្ថភាពរបស់កុមារក្នុងការស្រូបយកនូវអត្ថប្រយោជន៍នានាដែលទទួលបានពីការសិក្សា។

**ឧប្បត្តិហេតុនៃជំងឺ និងការរងរបួសដែលទាក់ទងនឹងការងារ មានកំរិតខ្ពស់សំរាប់កុមារធ្វើការនៅក្នុងប្រទេសកម្ពុជា។** នេះបង្ហាញថា ការងាររបស់កុមារតែងតែមានស្ថានភាពប្រកបដោយគ្រោះថ្នាក់។ មនុស្សធំដែល

ត្រូវបានសំភាសន៏សំរាប់ CCLS ឆ្នាំ ២០០១ បានបង្ហាញថា ស្ទើរតែពាក់កណ្តាលនៃចំនួនកុមារធ្វើការទាំងអស់ក្នុងប្រទេសកម្ពុជា ទទួលរងនូវបញ្ហាសុខភាពដែលបង្កមកពីការងារ ។ លទ្ធផលក៏បានបង្ហាញផងដែរថា លទ្ធភាពនៃការទទួលរងនូវបញ្ហាសុខភាពដែលបង្កមកពីការងារ ធ្លាក់ចុះទៅតាមអាយុរបស់កុមារ ។ នេះបង្ហាញថា កន្លែងការងារមានលក្ខណៈគ្រោះថ្នាក់ខ្លាំងសំរាប់កុមារក្មេងៗ ។ ការទទួលរងនូវបញ្ហាសុខភាពរបស់ក្មេងស្រីមានចំនួនតិចជាងការទទួលរងនូវបញ្ហាសុខភាពរបស់ក្មេងប្រុសចំនួន ២ ភាគរយ ។ នេះបញ្ជាក់ថា ស្ថានភាពការងារដែលធ្វើដោយក្មេងប្រុស មានលក្ខណៈខុសពីស្ថានភាពការងារដែលធ្វើដោយក្មេងស្រី ។

**លទ្ធផលអវិជ្ជមានក៏បានបង្ហាញទៀតផងដែរថា ទាំងការងារពេញម៉ោង និងការងារតាមវិស័យនានា បង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាពរបស់កុមារយ៉ាងខ្លាំង ។** រៀងរាល់ម៉ោងធ្វើការងារតាមសប្តាហ៍បានបន្ថែម ០,៣ ភាគរយថែមទៀតទៅលើលទ្ធភាពដែលអាចធ្លាក់ខ្លួនឈឺ ។ គ្រោះថ្នាក់នៃបញ្ហាសុខភាពដែលបង្កមកពីការងារ មានលក្ខណៈខុសៗគ្នាទៅតាមវិស័យការងារ ។ ឧទាហរណ៏ កុមារកម្ពុជាដែលធ្វើការនៅក្នុងវិស័យកសិកម្ម មាន ១២ ភាគរយដែលទំនងជាទទួលរងនូវបញ្ហាសុខភាព ច្រើនជាងចំនួនកុមារដែលធ្វើការនៅក្នុងវិស័យផលិតកម្ម ។ ដើម្បីប្រឈមមុខជាមួយសនឹងបញ្ហាគ្រោះថ្នាក់នេះនៅគ្រប់វិស័យការងារទាំងអស់ កុមារត្រូវចុះបញ្ជីចំនួនម៉ោងធ្វើការខុសៗគ្នា ។ នេះគឺជាការរកឃើញគន្លឹះ ព្រោះវាបានចង្អុលបង្ហាញពីតំរូវការពិចារណាទៅលើទាំងវិស័យការងារ និង ការធ្វើការងារពេញម៉ោង ថាជាលក្ខណៈវិនិច្ឆ័យចំបងនៃការងារប្រកបដោយគ្រោះថ្នាក់ ។

## មូលហេតុដែលនាំឱ្យមានការងារកុមារ

**គ្រួសារភាគច្រើនបានលើកឡើងពីតំរូវការផ្នែកសេដ្ឋកិច្ចថាជាមូលហេតុដែលត្រូវសំរេចចិត្តបញ្ជូនកូនរបស់ខ្លួនទៅធ្វើការងារ ។** ក្នុងចំណោមកុមារ ៤ នាក់ មានកុមារ ៣ នាក់បានលើកឡើងពីបញ្ហាភាពក្រីក្រក្នុងគ្រួសារ និងបញ្ហាដែលត្រូវជួយរកប្រាក់ចំណូលដល់គ្រួសារ ថាជាមូលហេតុចំបង ។ សំរាប់កុមារធ្វើការច្រើនជាងពាក់កណ្តាលនៃចំនួនសរុប គ្រួសាររបស់ពួកគេបានបញ្ជាក់ថា ការឈប់ធ្វើការងារ នឹងបង្កឱ្យមានការធ្លាក់ចុះនូវកំរិតជីវភាពរបស់គ្រួសារ ឬ បង្កឱ្យមានបញ្ហាគំរាមកំហែងដល់ការរស់រានរបស់គ្រួសារ ។ ការងាររបស់កុមារ ហាក់ដូចជាមិនបានដើរតួនាទីជួយដល់លទ្ធភាពរបស់គ្រួសារក្នុងការបញ្ជូនកុមារចូលសាលារៀននោះទេ ។ អ្នកឆ្លើយតបតិចជាង ១ ភាគរយបានលើកឡើងថា ការចំណាយនៅសាលារៀន គឺជាមូលហេតុដែលនាំឱ្យកុមារធ្វើការងារ ។ អ្នកឆ្លើយតបក្នុងសមាមាត្រប្រហាក់ប្រហែលគ្នានេះ បានបញ្ជាក់ថា ការឈប់ធ្វើការនឹងជំរុញឱ្យកុមារចាកចោលសាលារៀន ។ វា

មានការចាប់អារម្មណ៍ដែលត្រូវកត់ចំណាំថា ក្នុងករណីដែលមិនមានឧបសគ្គផ្នែកហិរញ្ញវត្ថុ និងប្រសិនបើមានជំរើស គ្រួសារចំនួន ២ភាគ៣ នៃគ្រួសារសរុប នឹងជ្រើសរើសឱ្យកូនរបស់ទទួលការអប់រំ។

**ការរកឃើញនៃការវិភាគចំរុះ បានចង្អុលបង្ហាញពីកត្តាមួយចំនួនដែលជំរុញដល់ការសំរេចចិត្តរបស់គ្រួសារ ឱ្យកូនទៅសាលារៀន ឬឱ្យកូនទៅធ្វើការ។** (ក) ប្រាក់ចំណូលរបស់គ្រួសារ មានផលប៉ះពាល់ជាអវិជ្ជមានទៅលើ ផ្នែកផ្គត់ផ្គង់នៃពលកម្មកុមារ (ខ) ការឆាប់ចូលរៀនតាំងពីវ័យកុមារភាព អាចជួយកាត់បន្ថយនូវការផ្គត់ផ្គង់ ពលកម្មកុមារ (គ) វត្តមានរបស់កុមារដែលមានអាយុអាចចូលរៀនថ្នាក់មត្តេយ្យ អាចកាត់បន្ថយនូវអវត្តមាន របស់កុមារនៅក្នុងសាលារៀន ជាពិសេសសំរាប់ក្មេងស្រី (ឃ) មានសាលារៀន អាចជួយកាត់បន្ថយនូវការចូលរួម របស់កុមារក្នុងការងារ និងបង្កើនការចុះឈ្មោះចូលរៀន (ង) គុណភាពនៃការអប់រំក្នុងសាលារៀន អាចជួយធ្វើឱ្យ កុមារនៅបន្តមករៀន (ច) វត្តមាននៃសមាគមមាតាបិតា អាចជួយបង្កើនវត្តមានរបស់កុមារក្នុងសាលា និង អាច ជួយកាត់បន្ថយការងារកុមារ (ឆ) ការអប់រំរបស់ឪពុកម្តាយ ជាពិសេសការអប់រំរបស់មាតា អាចជួយកាត់បន្ថយ ផ្នែកផ្គត់ផ្គង់ពលកម្មកុមារ (ជ) កម្មសិទ្ធិឧបករណ៍ធ្វើកសិកម្មនានា មានទំនាក់ទំនងជាវិជ្ជមានទៅលើការផ្គត់ផ្គង់ ផ្នែកពលកម្មកុមារ (ឈ) កុមារដែលជាកូនបង្កើតរបស់គ្រួសារ ទំនងជាធ្វើការងារតិចតួច (ញ) កុមារដែលមិន មែនជាកូនខ្មែរ ទំនងជាត្រូវធ្វើការងារច្រើន (ដ) គ្រួសារដែលមានមេគ្រួសារជាស្ត្រីទំនងជាបញ្ជូនកូនរបស់ខ្លួន ទៅធ្វើការជាជាងទៅសាលារៀន។

## ការឆ្លើយតបថ្នាក់ជាតិចំពោះពលកម្មកុមារ

**ប្រទេសកម្ពុជាបានប្តេជ្ញាចំពោះក្របខ័ណ្ឌការងារផ្នែកច្បាប់ជាច្រើនទាក់ទងនឹងបញ្ហាពលកម្មកុមារ ប៉ុន្តែ នៅតែមានការខ្វះចន្លោះផ្នែកបទបញ្ញត្តិនានាទាក់ទងនឹងបញ្ហាពលកម្មកុមារ។** ឧទាហរណ៍ជាក់ស្តែង ច្បាប់ស្តីពី ការងាររបស់ប្រទេសកម្ពុជា មិនបានពង្រីកដល់ផ្នែកមិនរៀបរយទេ ប៉ុន្តែគេឃើញមានចំនួនកុមារធ្វើពលកម្ម នៅក្នុងផ្នែកនោះច្រើនទៅវិញ។ ប្រការនេះមានន័យថា វិស័យកសិកម្មបែបគ្រួសារ និង វិស័យបំរើតាមផ្ទះ មិនត្រូវ បានគ្របដណ្តប់ដោយបទបញ្ញត្តិនោះទេ។ ច្បាប់ស្តីពីការងារ មិនបានកំណត់ឱ្យបានច្បាស់ពីនិយមន័យនៃពលកម្ម កុមារទេ ដូចជា ប្រភេទការងារ លក្ខខ័ណ្ឌការងារ និង គ្រោះថ្នាក់ការងារ។ ការអនុវត្តន៏ច្បាប់ទាក់ទងនឹងបញ្ហា ពលកម្មកុមារ គឺជាបញ្ហាប្រឈមមុខមួយទៀតដែលរដ្ឋាភិបាលកំពុងជួបប្រទះ។ នៅពេលបច្ចុប្បន្ននេះ រដ្ឋាភិបាល បានអនុញ្ញាត ប៉ុន្តែរដ្ឋាភិបាលមិនទាន់មានសមត្ថភាពអនុវត្ត និងត្រួតពិនិត្យលើការអនុវត្តន៏ច្បាប់ទាក់ទងនឹងបញ្ហា ពលកម្មកុមារនោះទេ។

ផែនការអភិវឌ្ឍន៍ជាតិរបស់ប្រទេសកម្ពុជា មានបង្ហាញនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២ (SEDP II) យុទ្ធសាស្ត្រកាត់បន្ថយភាពជាតិ (NPRS) គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDG) ឆ្នាំ ២០០៣ និង ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ឆ្នាំ ២០០៦-២០១០។ ក្នុងចំណោមឯកសារទាំងនេះ ឯកសារស្តីពី CMDG និង ឯកសារ NPRS បានដាក់បញ្ចូលនូវគោលដៅកាត់បន្ថយពលកម្មកុមារ។ ឯកសារ CMDG បានកំណត់គោលដៅកាត់បន្ថយសមាមាត្រពលកម្មកុមារដែលមានអាយុ ៥-១៧ ឆ្នាំ ចាប់ពី ១៦,៥ ភាគរយក្នុងឆ្នាំ ១៩៩៩ ដល់ ១៣ ភាគរយក្នុងឆ្នាំ ២០០៥ និង ចាប់ពី ១០,៦ ភាគរយក្នុងឆ្នាំ ២០១០ ដល់ ៨ ភាគរយក្នុងឆ្នាំ ២០១៥។ ឯកសារ NPRS បានកំណត់គោលដៅកាត់បន្ថយការចូលរួមក្នុងការងាររបស់កុមារដែលមានអាយុចាប់ពី ១០-១៤ ឆ្នាំ ចាប់ពី ៨,៣ ភាគរយក្នុងឆ្នាំ ១៩៩៩ ដល់ ៥,៣ ភាគរយក្នុងឆ្នាំ ២០០៥។

## ជំរុញការរីកចំរើនឆ្ពោះទៅកាន់ការលុបបំបាត់ពលកម្មកុមារ

**ការសំរេចបាននូវគោលដៅកាត់បន្ថយពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ទាមទារឱ្យមាននូវវិធានការទប់ស្កាត់ និងការពាររួមគ្នា** ដល់ក្រុមគោលដៅសំខាន់ៗ ៣ គឺ (១) ក្រុមកុមារដែលប្រឈមមុខនឹងការធ្លាក់ចូលក្នុងពលកម្មកុមារ (២) "ស្តុក" ក្រុមកុមារដែលកំពុងតែស្ថិតនៅក្នុងពលកម្មកុមារ និង (៣) ក្រុមអតីតពលកម្មកុមារដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ដោយសារតែបទពិសោធន៍របស់ខ្លួន។ វិធានការ "ទប់ស្កាត់" ត្រូវធ្វើឡើងដើម្បីកាត់បន្ថយលំហូរនៃការធ្លាក់ចូលទៅក្នុងពលកម្មកុមាររបស់កុមារងាយរងគ្រោះ និង ដើម្បីបញ្ឈប់កុមារដែលកំពុងធ្វើពលកម្មកុំឱ្យធ្លាក់ចូលទៅក្នុងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ ចំណែកឯវិធានការ "ការពារ" ត្រូវធ្វើឡើងដើម្បីស្វែងរក និង ការពារសុវត្ថិភាពដល់កុមារដែលបានធ្លាក់ចូលទៅក្នុងពលកម្មកុមារ ដើម្បីផ្តល់សេវាស្តារឡើងវិញ សេវាស្តារនីតិសម្បទា និង ដើម្បីទប់ស្កាត់កុមារកុំឱ្យធ្លាក់ចូលក្នុងពលកម្មកុមារម្តងទៀត។

**ការវិភាគតាមបទពិសោធន៍ដែលបានធ្វើឡើងសំរាប់ការសិក្សានេះ និងបទពិសោធន៍ផ្នែកគោលនយោបាយនៅក្នុងប្រទេសកម្ពុជានិងប្រទេសដទៃទៀតបានចង្អុលបង្ហាញពីវិធានការទប់ស្កាត់និងការពារមួយចំនួនដើម្បីឈានចាប់ដល់ក្រុមគោលដៅទាំង៣ខាងលើ។** ឧបករណ៍កាត់បន្ថយគ្រោះថ្នាក់ក្នុងសង្គម (ធានារ៉ាប់រងឥណទានខ្នាត តូច ការផ្ទេរសាច់ប្រាក់ ។ល។) ការកែលំអសេវា និងគុណភាពអប់រំ (ការអប់រំសំរាប់កុមារភាព) ការកែលំអ ប្រព័ន្ធផ្តល់សេវាកម្ម និង ការអប់រំដល់ឪពុកម្តាយ គឺជាវិធានការដ៏មានសារៈសំខាន់ក្នុងការទប់ស្កាត់កុមារកុំឱ្យធ្លាក់ ចូលទៅក្នុងពលកម្មកុមារ។ ការកែលំអឧបករណ៍អធិការកិច្ចតាមកន្លែងការងារក្នុងផ្នែករៀបរយ និង ការពង្រីក

យន្តការត្រួតពិនិត្យនៅតាមមូលដ្ឋាន នឹងក្លាយជាវិធានការសំខាន់ក្នុងការកំណត់ស្វែងរក និងការពារដល់កុមារដែលបានធ្លាក់ចូលក្នុងពលកម្មកុមាររួចហើយ។ សេវាស្តារនីតិសម្បទា រួមមានសេវាអប់រំត្រឹមត្រូវនៅតាមមជ្ឈមណ្ឌលសំចតនានា នឹងក្លាយជាវិធានការដ៏សំខាន់ក្នុងការធ្វើសមាហរណកម្មអតីតពលកម្មកុមារប្រកបដោយជោគជ័យ។

**ការរីកចំរើនឆ្ពោះទៅកាន់ការកាត់បន្ថយពលកម្មកុមារថ្នាក់ជាតិ ក៏ត្រូវពឹងផ្អែកទៅលើវិធានការធានាជំរុញបរិដ្ឋានផ្នែកគោលនយោបាយ ផ្នែកច្បាប់ និង ផ្នែកស្ថាប័ន។** ការប្តេជ្ញាផ្នែកគោលនយោបាយ ត្រូវធ្វើឡើងដើម្បីធានាបញ្ជ្រាបបញ្ហាពលកម្មកុមារទៅក្នុងផែនការ និងកម្មវិធីអភិវឌ្ឍ។ ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ទោះបីជាទើបបង្កើតឡើងក្តី ត្រូវធ្វើការពង្រឹងបន្ថែម និងបញ្ជាក់ឡើងវិញពីតួនាទីរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ។ ព័ត៌មានស្តីពីពលកម្មកុមារក្នុងបរិបទធំធេង ត្រូវមានជាចាំបាច់សំរាប់បង្កើតគោលនយោបាយ និងកំណត់ក្រុមគោលដៅឱ្យមានប្រសិទ្ធិភាព។ បទបញ្ញត្តិលំអិតដែលទាក់ទងនឹងបទដ្ឋានពលកម្មកុមារអន្តរជាតិ ត្រូវមានជាចាំបាច់ដើម្បីបង្កើតក្របខ័ណ្ឌការងារផ្នែកច្បាប់ទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ។ ការលុបបំបាត់ពលកម្មកុមារ ក៏ទាមទារឱ្យមានការចូលរួមពីសង្គម និងសហគមន៍ដែលមានពលកម្មកុមារក្នុងការផ្សព្វផ្សាយ និង ស្វែងរកការគាំទ្រប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ ។

តើមានវិធានការអ្វីផ្សេងទៀត ដែលត្រូវកត់ត្រាចូលទៅក្នុងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារទាំងនេះ? បន្ទុកការងារសំខាន់ក្នុងការកាត់បន្ថយពលកម្មកុមារ និង ការបង្កើនការវិនិយោគលើធនធានមនុស្ស គឺពឹងផ្អែកទៅលើវិធានការស្តីពីការទប់ស្កាត់។ ច្បាស់ណាស់ថា ការកាត់បន្ថយពលកម្មកុមារប្រកបដោយនិរន្តភាពមិនអាចធ្វើបាននោះទេ ប្រសិនបើមិនដោះស្រាយកត្តាដែលបង្កឱ្យកុមារធ្លាក់ខ្លួនចូលក្នុងពលកម្មកុមារ។ ដើម្បីផ្លាស់ប្តូរនូវបរិដ្ឋានផ្នែកសេដ្ឋកិច្ចសង្គមរបស់ក្រុមគ្រួសារ គោលនយោបាយស្តីពីការទប់ស្កាត់ ត្រូវកំណត់គោលដៅទៅលើការផ្លាស់ប្តូរឱ្យមានតុល្យភាពរវាងកំរិតពលកម្មកុមារ និងកំរិតនៃការចុះឈ្មោះចូលរៀន។

ប៉ុន្តែ គោលនយោបាយស្តីពី "ការការពារ" វិញ ក៏មិនត្រូវបំភ្លេចផងទេ។ គោលនយោបាយទាំងនេះ មានសារៈសំខាន់ក្នុងការជៀសវាងកុំឱ្យមានចំនួនកុមារច្រើនពេកធ្លាក់ចូលទៅក្នុងស្ថានភាពចាញ់ប្រៀបគេពេលធំឡើង ឬ ទទួលរងគ្រោះថ្នាក់ជាប្រចាំដោយសារតែបទពិសោធន៍កាលពីក្មេងរបស់ខ្លួន។ កុមារដែលមានការអប់រំតិចតួច ឬមិនមានការអប់រំ នឹងទទួលបានឋានៈតូចទាបនៅក្នុងទីផ្សារការងារ ព្រមទាំងប្រឈមមុខខ្លាំងទៅនឹងភាពមិនមានការងារធ្វើ ឬ ភាពក្រីក្រ។ កុមារ និងយុវវ័យទាំងនេះ ប្រសិនបើទុកមិនអើពើ នោះយើងនឹងត្រូវបង្កើតគោលនយោបាយផ្សេងទៀត (ចំណាយអស់ច្រើនជាងនេះទៅទៀត) នៅពេលដែលពួកគេធំឡើង។